**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជតក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១២

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 30-Nov-2012, 15:31
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខឆ្លាមៗរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងវិសាលភាព នៃសំណុំរឿង ០០២/០១**

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្តីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម យ៉ា ណារិន

ចៅក្រម Florence Ndepele Mwachande MUMBA

**ជំនួយការ៖**
លោកស្រី សេង សុជាតា
កញ្ញា Marie CAPOTORTO
កញ្ញា Shéhérazade BOUARFA
កញ្ញា Mathilde CHIFFERT
កញ្ញា អ៊ួច ស្រីផាត់
កញ្ញា ឈុន សុធារី
លោក Pierre TOUCHE

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

## I. ការរំលឹកអំពីនីតិវិធី

១. កាលពីថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានចេញសេចក្តីសម្រេចបំបែកការចោទប្រកាន់ ("ដីកាបំបែកសំណុំរឿង") ដែលអង្គជំនុំជម្រះត្រូវបានប្តឹង តាមរយៈដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២[1]។ អង្គជំនុំជម្រះក៏បានកម្រិតនូវវិសាលភាពនៃរឿងក្តីបច្ចុប្បន្ន ឱ្យនៅត្រឹមការពិនិត្យលើបទចោទដែលមានមូលដ្ឋានផ្អែកលើការជម្លៀសប្រជាជន ក្នុងដំណាក់កាលទី ១ និងទី ២ និងចំពោះអង្គហេតុដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលរួមមានអំពើមនុស្សឃាត ការបង្ខាំងមនុស្សដោយខុសច្បាប់ ការធ្វើទុក្ខបុកម្នេញ (លើកលែងតែមានមូលហេតុខាងសាសនា) ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ (ក្នុងករណីដែលពាក់ព័ន្ធទៅនិងបទចោទ ដែលមានមូលដ្ឋានផ្អែកលើការជម្លៀសប្រជាជនក្នុងដំណាក់កាលទី ១ និងទី ២[2]។

២. កាលពីថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានស្នើសុំទៅអង្គជំនុំជម្រះឱ្យធ្វើការពិនិត្យឡើងវិញនូវដីកាបំបែកសំណុំរឿង[3]។ កាលពីថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានបដិសេធនូវរាល់សំណើសុំទាំងឡាយណា ដែលមានកម្មវត្ថុជាការស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការពិនិត្យឡើងវិញលើដីកានេះ[4]។

---

[1] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **E124**។

[2] យោងដូចខាងលើ កថាខណ្ឌ ៥។

[3] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E124/2**។

[4] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E124/7**។

៣. កាលពីថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ *"[ដោយមានការ] ព្រួយបារម្ភថា ការជំនុំជម្រះក្តីដំណាក់កាលដំបូងនៅក្នុងសំណុំរឿងលេខ 00២ ដែលទាក់ទងនឹងការជម្លៀសប្រជាជនចេញនេះ អាចបង្កើតជាកេរ្តិ៍តំណែលរបស់អង្គជំនុំជម្រះនេះ សម្រាប់ប្រជាជនកម្ពុជា"* សហព្រះរាជអាជ្ញា បានស្នើសុំដល់អង្គជំនុំជម្រះ ឲ្យធ្វើការបញ្ចូលនូវទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្មដទៃទៀត ទៅក្នុងសំណុំរឿងបច្ចុប្បន្ន[5] ("សំណុំរឿងទី១")។

៤. កាលពីថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានបើកកិច្ចប្រជុំរៀបចំសវនាការមួយ ដើម្បីធ្វើការពិភាក្សា រវាងភាគី អំពីសំណើសុំរបស់សហព្រះរាជអាជ្ញា។ នាពេលនោះ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា៖ *"ការយល់ព្រមតាមសំណើខ្លះៗ ពាក់ព័ន្ធនឹងការស្នើសុំពង្រីកវិសាលភាពនៃសំណុំរឿង 00២/0១ នេះ តម្រូវឲ្យមានដំណោះស្រាយលើបញ្ហាមួយចំនួន និងតម្រូវឲ្យមានការពន្យារពេលវេលានៃកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង 00២/0១"*[6]។

៥. កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធទៅនិងសំណើសុំនេះ ក្រោមរូបភាពជាអនុស្សរណៈមួយ[7]។ អង្គជំនុំជម្រះបានសម្រេចទទួលយកសំណើសុំនោះមួយផ្នែក ដោយបានសម្រេចបញ្ចូលទៅក្នុងសំណុំរឿងនូវអង្គហេតុដែលពាក់ព័ន្ធទៅនឹងទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្មនៅទួលពោធិជ្រៃ[8]។ ក្រៅអំពីនេះ អង្គជំនុំជម្រះបានបដិសេធចោលនូវសំណើសុំឲ្យមានការពង្រីកនូវវិសាលភាពនៃសំណុំរឿងបច្ចុប្បន្នរហូតដល់មន្ទីរ ស.២១ និងទៅដល់ស្រុក ១២ ដោយអង្គជំនុំជម្រះបានលើកឡើងថា ការបដិសេធនេះមានមូលហេតុនៅត្រង់ថា

---

[5] សំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង 00២/0១ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ ឯកសារ **E163**។

[6] ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង 00២/0១ និងការអនុវត្តវិធានការបន្ថែម ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ, អនុស្សរណៈចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ ឯកសារ **E218**។

[7] សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅ ក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង 00២/0១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋាន បញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន, អនុស្សរណៈចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ ឯកសារ **E163/5** (តទៅនេះហៅថា "សេចក្តីសម្រេចដែលរងការជំទាស់")។

[8] យោងដូចខាងលើ កថាខណ្ឌ ៣។

*"ការដាក់បញ្ចូលធាតុផ្សំទាំងនេះ [...] នឹងអាចធ្វើឱ្យសវនាការលើសំណុំរឿង ០០២/០១ អូសបន្លាយពេលយូរ"*[9]។

៦. កាលពីថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ភាគីបានទទួលនូវសេចក្តីជូនដំណឹងជាភាសាអង់គ្លេស និងជាភាសាខ្មែរ អំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងសំណើសុំឱ្យមានការពង្រីកវិសាលភាពនៃសំណុំរឿង ០០១ មកក្នុងសំណុំរឿង ០០២[10] របស់ខ្លួន។

៧. កាលពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ មេធាវីការពារក្តីលោក ខៀវ សំផន បានស្នើសុំដល់អង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") ឱ្យធ្វើការពន្យាពេលសម្រាប់ការធ្វើចម្លើយតបរបស់ខ្លួន ពោលគឺរយៈពេលដែលផ្តល់ឱ្យក្នុងការធ្វើចម្លើយតបនេះ នឹងចាប់ផ្តើមគិតក្រោយពីពេលដែលមានការជូនដំណឹងអំពីបណ្តឹងសាទុក្ខជាបីភាសាផ្លូវការរបស់ អ.វ.ត.ក[11]។ នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារបកប្រែ "បណ្តឹងសាទុក្ខ" ជាភាសាបារាំង ត្រូវបានធ្វើជូនភាគី ហើយអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចតាមសំណើសុំរបស់សហមេធាវីការពារក្តីលោក ខៀវ សំផន[12]។

## II. <u>ភាពមិនអាចទទួលយកបាននៃបណ្តឹងសាទុក្ខ</u>

**ទឡ្ហីករណ៍ដែលបង្ហាញថា វិធាន ១០៤-៤-ក នៃវិធានផ្ទៃក្នុងបានចែងអំពីបណ្តឹងសាទុក្ខ ក្នុងករណីដែលលទ្ធភាពដែលអាចមាននីតិវិធីបន្ទាប់ ស្ថិតនៅឆ្ងាយ ឬមើលមិនឃើញ**[13]

[9] យោងដូចខាងលើ កថាខណ្ឌ ២។

[10] *បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំ រឿងលេខ ០០២/០១ មានឧបសម្ព័ន្ធ (I) និងឧបសម្ព័ន្ធសម្ងាត់ (II)* ចុះថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ **E163/5/1/1** ("តទៅនេះ ហៅថា "បណ្តឹងសាទុក្ខ")។

[11] សំណើជាបន្ទាន់របស់មេធាវីការពារក្តី ខៀវ សំផន សុំពន្យារពេលដាក់សារណាតប ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ **E163/5/1/2**។

[12] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តី ខៀវ សំផន សុំពន្យារពេលធ្វើការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខ ភ្លាមៗរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ **E163/5/1/2/1**។

[13] "បណ្តឹងសាទុក្ខ" កថាខណ្ឌ ១១-១៩។

៨. បណ្តឹងសាទុក្ខមិនអាចទទួលយកបាន ហើយត្រូវតែបានបដិសេធចោលតាំងតែពីដំបូង។ ជាក់ស្តែង សហព្រះរាជអាជ្ញាបានដាក់បណ្តឹងសាទុក្ខរបស់ខ្លួន ដោយអនុវត្តតាមវិធាន ១០៤-៤-ក។ ដោយឡែក បទបញ្ញត្តិនេះមិនអាចយកមកអនុវត្តក្នុងករណីជាក់ស្តែងបានទេ៖ វិធាន ១០៤-៤-ក បានចែងថា មានតែសេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីទេ ដែលអាចត្រូវបានប្តឹងសាទុក្ខភ្លាមៗបាន។ វាពុំមែនជាករណីនៃអនុស្សារណៈរបស់អង្គជំនុំជម្រះចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ ទេ[14]។

៩. សហព្រះរាជអាជ្ញាបានអះអាងថា កាលពីពេលមុន តុលាការកំពូលគួរតែផ្តល់នូវការបកស្រាយស៊ីជម្រៅលើវិធាន ១០៤-៤-ក។ វិធាននេះក៏ត្រូវបានអនុវត្តចំពោះសេចក្តីសម្រេចទាំងឡាយរបស់អង្គជំនុំជម្រះ ទោះបីជាសេចក្តីសម្រេចទាំងនោះពុំបានបញ្ចប់តាមផ្លូវច្បាប់នូវកិច្ចដំណើរការនីតិវិធីក៏ដោយ *ឲ្យតែសេចក្តីសម្រេចទាំងនោះពុំបានផ្តល់នូវទស្សនាទានច្បាស់លាស់ថា នឹងមានការបន្តនីតិវិធី [ ហើយ ដូច្នេះ] បានបញ្ចប់កិច្ចដំណើរការនីតិវិធីតែម្តង"* [15] ។ អំណះអំណាងរបស់សហព្រះរាជអាជ្ញាខាងលើនេះមានការខុសឆ្គង ហើយពឹងផ្អែកតែទៅលើការអានមួយផ្នែកនៃសេចក្តីសម្រេច ដែលជាមូលដ្ឋាននៃបណ្តឹងរបស់ខ្លួនប៉ុណ្ណោះ។ ជាក់ស្តែង សេចក្តីសម្រេចរបស់តុលាការកំពូលដូចបានបញ្ជាក់ខាងលើនេះ មានលក្ខណៈច្បាស់លាស់ជាង ដោយហេតុសេចក្តីសម្រេចនោះបានលើកឡើងថា "*<u>ការផ្អាកនីតិវិធី</u> ដែលធ្វើឡើងដោយពុំមានតម្រុយច្បាស់លាស់ណាមួយដែលថានឹងមានការបន្តនីតិវិធីឡើងវិញទេនោះ ទង្វើនេះបានបញ្ចប់ដល់នីតិវិធីទាំងស្រុង ហើយ **សាលក្រមលើអង្គសេចក្តីមួយមិនអាចត្រូវបានចេញកើតឡើយ***" [16]។ ជាក់ស្តែង សេចក្តីសម្រេចដែលរងការជំទាស់ ពុំបានបង្កើតឲ្យមានជា "*ការផ្អាកនីតិវិធី* " ទេ ហើយក៏ពុំបានរាំងស្ទះដល់ការចេញសាលក្រមលើអង្គសេចក្តីដែរ។ ផ្ទុយទៅវិញ សេចក្តីសម្រេចនោះមានខ្លឹមសារពាក់ព័ន្ធនឹងការរៀបចំកិច្ចដំណើរការរបស់តុលាការបច្ចុប្បន្នទៅវិញទេ។

---

[14] "សេចក្តីសម្រេចដែលរងការជំទាស់"។

[15] "បណ្តឹងសាទុក្ខ" កថាខណ្ឌ ១១។

[16] *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ* ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ **E138/1/7** កថាខណ្ឌ ១៤។ បកប្រែក្រៅផ្លូវការ។ [គូសបញ្ជាក់បន្ថែមដោយអ្នកតាក់តែង]។

១០. ដោយឡែក វាជារឿងមួយសំខាន់ក្នុងការកត់សម្គាល់ថា នៅក្នុងសំណើរសុំរបស់ខ្លួនដែលមានគោលដៅស្នើឲ្យមានការពិនិត្យឡើងវិញលើដីកាបំបែកសំណុំរឿង ចេញនាខែ តុលា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានទទួលស្គាល់ដោយខ្លួនឯងថា សេចក្តីសម្រេចបំបែកការចោទប្រកាន់ គឺជា *"សេចក្តីសម្រេចដែលពាក់ព័ន្ធនឹងការរៀបចំតុលាការ"* ហើយ *"ករណីនេះមិនអាចត្រូវបានប្តឹងសាទុក្ខភ្លាមៗបានទេ"* [17]។ សេចក្តីសម្រេចដែលត្រូវបានប្តឹងសាទុក្ខក៏ពុំមានលក្ខណៈខុសគ្នាដែរ៖ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចគ្រប់គ្រងសវនាការ ដោយគិតអំពី *"ហានិភ័យដែលថាការពង្រីកវិសាលភាពនៃសំណុំរឿងទីមួយឲ្យគ្របដណ្តប់លើអង្គហេតុបន្ថែមទាំងពីរសណ្ឋាន នឹងបង្កើតឲ្យមានជាការពន្យាពេលហួសហេតុដល់កិច្ចពិភាក្សាដេញដោល"* [18] ។ ជាមួយគ្នានេះ ដោយលើកអំណះអំណាងថា សេចក្តីសម្រេចដែលត្រូវបានប្តឹងសាទុក្ខបានបញ្ចប់កិច្ចដំណើរការនីតិវិធី សហព្រះរាជអាជ្ញាបានព្យាយាមពង្រីកយ៉ាងហួសហេតុនូវវិសាលភាពនៃវិធាន ១០៤-៤។

១១. ម្យ៉ាងវិញទៀត នាខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានរំលឹករួចមកហើយថា *"ពុំមានការចោទប្រកាន់ ឬបទចោទនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានគេបោះបង់ ចោលឡើយ"* [19]។ ជាក់ស្តែង បច្ចុប្បន្ននេះ សហព្រះរាជអាជ្ញាបានទទួលស្គាល់ថា ការបកស្រាយទូលំទូលាយលើពាក្យដែលថា "*មានអនុភាពបញ្ចប់នីតិវិធី*" មានលក្ខណៈត្រឹមត្រូវ ដោយហេតុថា ភាពផ្ទាស់គ្នាតែមួយគត់ដែលអាចកើតមានឡើង គឺនៅត្រង់ថាបណ្តឹងសាទុក្ខ ដំណាលគ្នានិងសាលក្រមលើអង្គសេចក្តី ហើយជាក់ស្តែង សាលក្រមនេះនឹងមិនអាចត្រូវបានចេញរួចឡើយ[20]។ ការប្រកាន់ជំហរបែបនេះ មានលក្ខណៈផ្ទុយគ្នាទៅនឹងវិសាលភាពដ៏តូចចង្អៀតនៃវិធាន ១០៤-៤ ដែលវិធាននេះបានកំណត់លក្ខខណ្ឌ ចំនួន ៤ ពាក់ព័ន្ធដល់ការធ្វើបណ្តឹងសាទុក្ខភ្លាមៗនោះ។

---

[17] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E124/2** កថាខណ្ឌ ១៦។

[18] "សេចក្តីសម្រេចដែលរងការជំទាស់" កថាខណ្ឌ ២។

[19] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E124**/7 កថាខណ្ឌ ៩។

[20] "បណ្តឹងសាទុក្ខ" កថាខណ្ឌ ១២ និង ១៣។

១២. លើសពីនេះ គេអាចទឹកឃើញផងដែរថា ក្នុងឱកាសមួយចំនួនផ្សេងទៀត សហព្រះរាជអាជ្ញាក៏ធ្លាប់បានលើកឡើងអំពីវិសាលភាពដ៏តូចចង្អៀតនៃវិធាន ១០៤-៤ ដោយរំលឹកអំពីការច្រានចោលក្នុងអំឡុងនៃកិច្ចប្រជុំពេញអង្គនាខែ កុម្ភៈ ឆ្នាំ ២០១១ នូវការធ្វើវិសោធនកម្មដែលមានគោលដៅពង្រីកវិសាលភាពនៃការធ្វើបណ្តឹងសារទុក្ខភ្លាមៗនោះ[21]។

១៣. ដូចគ្នានេះដែរ ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាដែលថា បណ្តឹងសាទុក្ខរបស់ខ្លួនត្រូវតែអាចទទួលយកបាន ដោយហេតុថា ប្រសិនណាជាមិនអាចទទួលយកបានទេនោះ សហព្រះរាជអាជ្ញានឹងមិនអាចមានលទ្ធភាពនាពេលក្រោយ ក្នុងការធ្វើបណ្តឹងណាមួយដើម្បីស្នើសុំឱ្យមានការទទួលយកទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានគេដកចេញ ទឡ្ហីករណ៍ដូចនេះមិនអាចទទួលយកបានឡើយ។ ជាក់ស្តែង តុលាការកំពូលធ្លាប់បដិសេធចោលនូវបណ្តឹងសាទុក្ខភ្លាមៗ ទោះបីជាបណ្តឹងសាទុក្ខទន្ទឹមគ្នានិងសាលក្រមលើអង្គសេចក្តី ជាក់ស្តែង មិនអនុញ្ញាតិឱ្យមានការកែប្រែព្យសនកម្មក៏ដោយ[22]។

១៤. ដោយឡែក សហព្រះរាជអាជ្ញាបានទទួលស្គាល់ថា វាជារឿងមួយសមហេតុសមផលក្នុងការលើកឡើងថា នឹងពុំមានរឿងក្តីណាមួយផ្សេងទៀតទេនៅក្នុងសំណុំរឿង ០០២ នោះ ឬថាការបន្តជំនុំជម្រះរឿងក្តីទាំងនោះគឺជាលទ្ធភាពមួយដែលនៅសែនឆ្ងាយ ពោលគឺមិនអាចកើតមានទៀរួចនោះ[23]។ សហព្រះរាជអាជ្ញាបានលើកអំណះអំណាងរបស់ខ្លួនដោយផ្អែកទៅលើមូលដ្ឋាននៃអាយុដ៏ចាស់ជរារបស់ជនជាប់ចោទ ដោយហេតុថា អាយុកាលជាមធ្យមនៃបុរសនៅប្រទេសកម្ពុជាគឺ

---

[21] *ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងការជូនដំណឹងអំពីបណ្តឹងសាទុក្ខចំនួនពីររបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធការពន្យារពេល និងចំនួនទំព័រកំណត់សម្រាប់ការដាក់អញ្ញត្រកម្មបឋម* ចុះ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១ ឯកសារ **E9/7/1/1/1/1** កថាខណ្ឌ ៥។

[22] ឧទាហរណ៍ សូមមើល៖ *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខដែលបានដាក់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២ និងក្រុម ៣ ប្រឆាំងនឹងសេចក្តីសម្រេចធ្វើឡើងដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩* ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារ **D288/6.169/1/2**; *សេចក្តីសម្រេចលើសេចក្តីជូនដំណឹងពីរនៃបណ្តឹងសាទុក្ខដែលដាក់ដោយ អៀង សារី* ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១ ឯកសារ **E9/7/1/1/1/4**; *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវ ស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **E95/8/1/4**។

[23] "បណ្តឹងសាទុក្ខ" កថាខណ្ឌ ១៥។

៥៧ ឆ្នាំ ប៉ុណ្ណោះ និងទៅលើហានិភ័យនៃភាពទ្រុឌទ្រោមផ្នែករាងកាយ និងស្មារតីរបស់ជនជាប់ចោទទៅតាមអាយុកាលរបស់ពួកគេ[24]។ គួរបញ្ជាក់ថា ក្នុងចំណោមតួលេខទាំងនោះ ពុំមានតួលេខណាមួយដែលថ្មីនោះទេ។ ជាមួយគ្នានេះ លោក ខៀវ សំផន ត្រូវបានចេញដីកាឃុំខ្លួននៅក្នុងអាយុ ៧៦ ឆ្នាំ។

១៥. ការពិត នៅក្នុងអំឡុងពេលកិច្ចប្រជុំរៀបចំសវនាការដូចបានបញ្ជាក់ខាងលើ សហព្រះរាជអាជ្ញាហាក់ដូចជាបង្ហាញថា ខ្លួនមានកង្វល់ជាក់ស្តែងពាក់ព័ន្ធទៅនិងហិរញ្ញប្បទានរបស់ អ.វ.ត.ក។ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានប្រកាសផងដែរថា៖ *"វាប្រាកដជាពុំមានការជំនុំជម្រះលើកទីពីរសម្រាប់សំណុំរឿង ០០២ ទេ [...] ម្យ៉ាងទៀត ធនធានហិរញ្ញវត្ថុរបស់តុលាការនេះកំពុងតែជួបនូវវិបត្តិ។ អត្ថបទមួយពាក់ព័ន្ធនិងប្រធានបទនេះត្រូវបានចុះផ្សាយនៅក្នុងទំព័រសារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ (The Phnom Penh Post) ផងដែរ ក្នុងថ្ងៃនេះ។ ទស្សនាទានដែលយល់ឃើញថា ការទទួលបាននូវធនធានហិរញ្ញវត្ថុបន្ថែមអនុញ្ញាតឲ្យគេអាចធ្វើការជំនុំជម្រះសំណុំរឿងមួយទៀតបាន ជាការយល់ឃើញមួយដែលមានសង្ឃឹមតិចតួចបំផុត ហើយខ្ញុំមានការយល់យ៉ាងជាក់ច្បាស់អំពីនិន្នាការនេះ"* [25]។ ពាក្យចចាមអារ៉ាមនានាដែលលេចឮនៅក្នុងទំព័រសារព័ត៌មានប្រចាំថ្ងៃរបស់ជាតិពុំមែនជាអំណះអំណាងគ្រប់គ្រាន់ដែលអាចឲ្យគេធ្វើសេចក្តីសន្និដ្ឋានបានយ៉ាងច្បាស់លាស់ថា នឹងពុំមានសំណុំរឿងទីពីរនោះទេ។ ករណីមិនទៀងទាត់ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុដែលតុលាការអន្តរជាតិនានាបានជួបប្រទះ ក្រោមរូបភាពនៃការធ្វើហិរញ្ញប្បទានខុសៗគ្នានោះ ពុំមែនជាលក្ខណៈវិនិច្ឆ័យមួយដែលបានកំណត់នៅក្នុងវិធាន ១០៤-៤ នោះទេ។

១៦. ក្នុងការគាំទ្រអំណះអំណាងរបស់ខ្លួន ដែលថាការបន្តជំនុំជម្រះសំណុំរឿងថ្មីមិនអាចធ្វើទៅបាននោះ សហព្រះរាជអាជ្ញាបានលើកឡើងថា *"អង្គជំនុំជម្រះសាលាដំបូងក៏បានលើកឡើងផងដែរអំពីការព្រួយបារម្ភណ៍ជាក់ស្តែងពាក់ព័ន្ធទៅនិងសម្បទាផ្នែករាងកាយ និងស្មារតីរបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការដ៏វែងអន្លាយមួយនោះ"*[26]។

---

[24] "បណ្តឹងសាទុក្ខ" កថាខណ្ឌ ១៦។

[25] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចប្រជុំរៀបចំសវនាការ (សាធារណៈ - កោសលុប) ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ឯកសារ **E1/114.1** ទំព័រ ៧៣ បន្ទាត់ ១១ ដល់ ១៧។

[26] "បណ្តឹងសាទុក្ខ" កថាខណ្ឌ ១៧។

១៧. នៅទីនេះ សហព្រះរាជអាជ្ញាបានពង្វាងសេចក្តីថ្លែងការណ៍នេះចេញពីបរិបទរបស់វា ខណៈដែលអង្គជំនុំជម្រះបានយល់ឃើញផ្ទុយទៅវិញ។ ជាក់ស្តែង អង្គជំនុំជម្រះបានសម្រេចថា៖ "*ដោយពិចារណាថា ពិតជាមានក្តីបារម្ភមួយថាតើជនជាប់ចោទនឹងអាចចូលរួមទាំងផ្លូវកាយ និងស្មារតីនៅក្នុងការជំនុំជម្រះដែលមានរយៈពេលវែង ឬយ៉ាងណា ដូចដែលសហព្រះរាជអាជ្ញាលើកឡើងនោះ អង្គជំនុំជម្រះបានចាត់ទុកវិធានការទាំងនេះថា មានសារៈសំខាន់ដើម្បី [ការពារ] ផលប្រយោជន៍ជាសារវន្តរបស់ជនរងគ្រោះ ក្នុងការទទួលបាននូវយុត្តិធម៌ប្រកបដោយអត្ថន័យ និងទាន់ពេលវេលា ព្រមទាំងការពារបាននូវសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័សនៅក្នុងសំណុំរឿង ០០២ ទៀតផង*"[27] ។

១៨. ជាទីបញ្ចប់ សហព្រះរាជអាជ្ញាស្នើសុំឱ្យតុលាការកំពូលធ្វើការបកស្រាយវិធាន ១០៤-៤ នៃវិធានផ្ទៃក្នុង ដោយពឹងផ្អែកលើវិធាន ២១ ដែលចែងថា វិធានផ្ទៃក្នុងត្រូវតែបានបកស្រាយ "*ក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព*"[28]។

១៩. ជាថ្មីម្តងទៀត សហព្រះរាជអាជ្ញាបានបង្ហាញអំពីភាពមិនស្មោះត្រង់របស់ខ្លួន ក្នុងការលើកនូវអំណះអំណាងដែលផ្ទុយទៅនឹងអំណះអំណាងដែលខ្លួនធ្លាប់បានលើកកាលពីពេលមុនៗ ជាមួយគ្នានេះ ក្នុងការលើកឡើងអំពីភាពដែលមិនអាចទទួលយកបាននៃបណ្តឹងសាទុក្ខភ្លាមៗ ដែលបានប្តឹងដោយក្រុមមេធាវីការពារក្តីលោក អៀង សារី សហព្រះរាជអាជ្ញាបានសរសេរថា "*វិធាន ២១ គឺជាបញ្ញត្តិទូទៅមួយដែលសម្រាប់យកមកអនុវត្ត ជាសំខាន់បំផុត ធ្វើជាវិធានមួយសម្រាប់ធ្វើការបកស្រាយ។ វិធាននេះមិនអាចលប់លើខ្លឹមសារដែលច្បាស់លាស់ និងដែលគ្មានភាពស្រពិចស្រពិលនៃវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុងនោះបានឡើយ ដែលក្នុងនោះបានចែងថា មានសេចក្តីសម្រេចតែបួនប្រភេទប៉ុណ្ណោះដែលអាចឱ្យធ្វើបណ្តឹងសាទុក្ខភ្លាមៗបាន និងរក្សាសិទ្ធិប្តឹងសាទុក្ខ*

[27] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E124/7** កថាខណ្ឌ ១១។

[28] "បណ្តឹងសាទុក្ខ" កថាខណ្ឌ ១៨។

*ប្រឆាំងនឹងរាល់សេចក្ដីសម្រេចទាំងអស់ដទៃទៀត នៅក្នុងដំណាក់កាលក្រោយៗទៀតនៃកិច្ចដំណើរការនីតិវិធី”*[29]។

២០. ប្រសិនណាជាគេអនុវត្តវិធានដូចគ្នាទៅលើភាគីទាំងអស់ ការអនុវត្តតាមវិធាន ២១ អាចនឹងមានអនុភាពជាការបំប្លែងនូវអត្ថន័យជាក់លាក់នៃវិធាន ១០៤-៤ ដោយហេតុថា ម្ដងនេះ វាស្ដែងឡើងជាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។ ដូច្នេះត្រូវស្នើសុំដល់តុលាការកំពូលឱ្យបដិសេធបណ្ដឹងនេះចោល។

## **ឧទ្ទិករណ៍ដែលថាបណ្ដឹងសាទុក្ខត្រូវបានដាក់នៅក្នុងរយៈពេលដែលបានកំណត់**[30]

២១. សហព្រះរាជអាជ្ញាយល់ស្របក្នុងការណ៍ដែលបណ្ដឹងសាទុក្ខត្រូវបានដាក់ក្នុងរយៈពេលដែលបានកំណត់ដោយវិធាន ១០៧-១ នៃវិធានផ្ទៃក្នុង ពោលគឺ ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់តាំងពីថ្ងៃចេញសេចក្ដីសម្រេចដែលត្រូវបានប្ដឹងសាទុក្ខ។ បើយោងតាមសហព្រះរាជអាជ្ញា រយៈពេលនេះចាប់ផ្ដើមរាប់តាំងពីពេលដែលមានសេចក្ដីសម្រេចដែលត្រូវបានប្ដឹងសាទុក្ខ ហើយពុំមែនចាប់ផ្ដើមគិតពីពេលដែលមានដីកាបំបែកសំណុំរឿង ឬសេចក្ដីសម្រេចពាក់ព័ន្ធនិងសំណើសុំឱ្យមានការពិនិត្យឡើងវិញនោះទេ ក្នុងករណីដែលសេចក្ដីសម្រេចទាំងពីរនេះបានទុកនូវលទ្ធភាពក្នុងការដាក់បញ្ចូលនូវបទចោទនានា ឬការចោទប្រកាន់លើអង្គហេតុបន្ថែមនោះ[31]។

២២. រយៈពេលនៃការធ្វើបណ្ដឹងសាទុក្ខមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញថា ការប្រកាសថាបណ្ដឹងសាទុក្ខអាចទទួលយកបាន នឹងបង្កើតឱ្យមានជាភាពរាំងស្ទះមួយទៅលើកិច្ចដំណើរការជំនុំជម្រះនាពេលបច្ចុប្បន្ន។ ជាក់ស្ដែង វិធាន១០៨-៤ ស្ទួន-ខ បានចែងថា *“អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចទាក់ទងនឹងវិធាន ១០៤(៤) (ក)*

[29] *ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធសំណើរបស់គាត់ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនរក្សាការប្រាស្រ័យទាក់ទងដោយចំហ និងដោយតម្លាភាពជាមួយភាគីទាំងអស់* ចុះថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ **E154/1/1/2** កថាខណ្ឌ ៩។ បកប្រែក្រៅផ្លូវការ។

[30] “បណ្ដឹងសាទុក្ខ” កថាខណ្ឌ ២០។

[31] យោងដូចខាងលើ។

*ក្នុងអំឡុងពេល ៣(បី)ខែ បន្ទាប់ពីទទួលបានឯកសារដូចមានចែងក្នុងកថាខណ្ឌ ២ នៃវិធាននេះ។ ក៏ប៉ុន្តែ ក្នុងករណីពិសេស អង្គជំនុំជម្រះតុលាការកំពូលអាចពន្យាថេរវេលានេះមួយខែបន្ថែមទៀត។ ប្រសិនបើសេចក្តីសម្រេចនេះមិនត្រូវបានចេញក្នុងរយៈពេលកំណត់នោះទេ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវតំកល់ទុកជាបានការ។"*

២៣. ជាក់ស្តែង សេចក្តីសម្រេចរបស់តុលាការកំពូលអាចត្រូវបានធ្វើក្នុងរយៈពេលលើសពី ៤ ខែ បន្ទាប់ពីមានសេចក្តីសម្រេចដែលត្រូវបានប្តឹងសាទុក្ខ។ រយៈពេលនេះមានលក្ខណៈសមស្រប នៅពេលដែលសេចក្តីសម្រេចដែលត្រូវបានប្តឹងសាទុក្ខបានបញ្ចប់កិច្ចដំណើរការនីតិវិធី។ ដោយឡែកជាក់ស្តែង វាពុំដូច្នោះឡើយ។ សវនាការលើអង្គសេចក្តីមិនត្រូវបានផ្អាកឡើយ។ នាខែ សីហា ឆ្នាំ ២០១២ បន្ទាប់ពីបានធ្វើការវាយតម្លៃអំពីភាពរាំងស្ទះដែលបណ្តាលមកពីវិសាលភាពមានព្រំដែនកំណត់នៃសំណុំរឿងទីមួយ អង្គជំនុំជម្រះបានសម្រេចថា *"ការយល់ព្រមតាមសំណើខ្លះៗ ពាក់ព័ន្ធនិងការស្នើសុំពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ នេះ តម្រូវឱ្យមានដំណោះស្រាយលើបញ្ហាមួយចំនួន និងតម្រូវឱ្យមានការពន្យារពេលវេលានៃកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០១។ ដោយសារសាក្សីជាច្រើននាក់ដែលអាចមានការពាក់ព័ន្ធទៅនឹងការពង្រីកវិសាលភាពដែលបានស្នើសុំនេះ មិនទាន់ត្រូវបានស្តាប់នៅចំពោះមុខអង្គជំនុំជម្រះនៅឡើយ ការព្រួយបារម្ភរបស់មេធាវីការពារក្តី អំពីការជូនដំណឹងឱ្យបានគ្រប់គ្រាន់អាចត្រូវបានដោះស្រាយនៅក្នុងដែនកំណត់នៃដំណើរការជំនុំជម្រះបច្ចុប្បន្ននេះ។"*[32]។

២៤. ការសម្រេចបញ្ចូលនូវទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្មថ្មីទៅក្នុងសំណុំរឿង ០០២/០១ ដែលអូសបន្លាយពេលអស់រយៈពេល ៤ ខែ នឹងបង្កនូវផលវិបាកធ្ងន់ធ្ងរដល់កិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន។ រយៈពេល ៤ ខែ នេះក៏ស្តែងបង្ហាញឱ្យឃើញថា បណ្តឹងសាទុក្ខមានលក្ខណៈយឺតយ៉ាវ បើគិតអំពីដំណើរប្រព្រឹត្តទៅនៃកិច្ចនីតិវិធីក្នុងសំណុំរឿង ០០២/០១។ ដូច្នេះ តុលាការកំពូលត្រូវបានស្នើសុំឱ្យបដិសេធនូវបណ្តឹងសាទុក្ខដោយផ្អែកលើមូលដ្ឋាននេះ។

---

[32] ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែម ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ ចុះថ្ងៃ ទី ៣ ខែ សីហា ឆ្នាំ ២០១២ ឯកសារ **E218** កថាខណ្ឌ ១៣-១៤។

## III. អវត្តមាននៃការរំលោភលើអំណាចឆន្ទានុសិទ្ធិដោយអង្គជំនុំជម្រះ

២៥. សហព្រះរាជអាជ្ញាយល់ស្របថា អង្គជំនុំជម្រះបានធ្វើហួសពីដែនអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការអនុវត្តយ៉ាងខុសឆ្គងនូវបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធនិងការបំបែកសំណុំរឿង[33]។

២៦. សហព្រះរាជអាជ្ញាបានអះអាងថា ក្នុងការដែលមិនសម្រេចបង្កើតឱ្យមាន "រឿងក្តីតូច"មួយ នៅក្នុងសំណុំរឿង ០០២/០១ ដែលតំណាងឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល អង្គជំនុំជម្រះ មានការធ្វេសប្រហែសទៅលើអត្ថប្រយោជន៍នៃយុត្តិធម៌[34] ទៅលើសិទ្ធិរបស់ជនរងគ្រោះ[35] "ការ ផ្សះផ្សារជាតិ"[36] ហើយអាចនឹងបង្កនូវព្យសនកម្មដែលមិនអាចជួសជុលបានចំពោះសហព្រះរាជ អាជ្ញាទៀតផង[37]។

២៧. ស្របទៅនឹងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី ("TPIY") សហព្រះរាជអាជ្ញាបានស្នើសុំដល់តុលាការកំពូលឱ្យធ្វើការសម្រេចថា សេចក្តីសម្រេចដែលត្រូវ បានប្តឹងសាទុក្ខ *"១) ត្រូវបានធ្វើដោយផ្អែកលើការបកស្រាយដោយខុសឆ្គងនូវច្បាប់ដែលត្រូវ អនុវត្ត។ ២) ផ្អែកលើសេចក្តីសន្និដ្ឋានដែលមានលក្ខណៈខុសឆ្គង ឬ ៣). ពាក់ព័ន្ធនិងចំណុចនេះ មានលក្ខណៈមិនត្រឹមត្រូវ ឬមិនសមហេតុផល ក្នុងការដែលមានកំហុសឆ្គងក្នុងការវាយតម្លៃពី សំណាក់អង្គជំនុំជម្រះសាលាដំបូង"*[38]។

---

[33] "បណ្តឹងសាទុក្ខ" កថាខណ្ឌ ២១ និងកថាខណ្ឌបន្តបន្ទាប់។

[34] យោងដូចខាងលើ កថាខណ្ឌ ២៣ និង ៣៦។

[35] យោងដូចខាងលើ កថាខណ្ឌ ២៣, ៣៨ និង ៣៩។

[36] យោងដូចខាងលើ។

[37] យោងដូចខាងលើ កថាខណ្ឌ ២៣។

[38] *រដ្ឋអាជ្ញា ទល់នឹង Jadranko Prlić និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-74 *"សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់សាលាដំបូងលើសំណើសុំដោះលែងជាបណ្តោះអាសន្ន ដែលបានដាក់ដោយ Slobodan Praljak"* សាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ចុះថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៩ កថាខណ្ឌ ៥។

២៨. ចំពោះបញ្ហានេះ សហព្រះរាជអាជ្ញាមានបំណងធ្វើការបង្ហាញដល់តុលាការកំពូលថា សេចក្តីសម្រេចស្តីអំពីការបំបែកសំណុំរឿង ពុំមែនពាក់ព័ន្ធតែទៅលើការអនុវត្តជាក់ស្តែងស្តីពីការគ្រប់-គ្រងសវនាការមួយប៉ុណ្ណោះទេ ប៉ុន្តែក៏ពាក់ព័ន្ធទៅនិងសិទ្ធិជាសារវន្តរបស់ភាគីផងដែរ[39]។

២៩. ដោយហេតុថា ដើម្បីធ្វើឱ្យសារណារបស់ខ្លួនមានមូលដ្ឋានរឹងមាំ ដែលតាមរយៈសារណានោះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះស្នើនិងការបញ្ចប់នីតិវិធី អំណះអំណាងនេះមានមូលដ្ឋានទាំងស្រុងផ្អែកទៅលើគោលការណ៍គ្រឹះដែលថា នឹងពុំមានការជំនុំជម្រះលើកទីពីរ[40]ឡើយ ជាពិសេស ដោយសារហេតុផលអាយុរបស់ជនជាប់ចោទនោះ[41]។

៣០. ផ្អែកលើអំណះអំណាងរបស់សហព្រះរាជអាជ្ញា ដីកាបំបែកសំណុំរឿងត្រូវតែបានចាត់ទុកថា ជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលផ្អែកលើមូលដ្ឋាននៃដីកានេះ នាំឱ្យមានការជំនុំជម្រះតែមួយគត់ និងសង្ខេប។ នេះជាមូលហេតុមួយ ដែលសហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះគួរតែពិចារណាអំពី "ភាពជាតំណាង" នៃបន្ទុកដែលត្រូវធ្លាក់ទៅលើជនជាប់ចោទ[42]។

៣១. ដោយឡែក អង្គជំនុំជម្រះពុំបានធ្វើការបំបែកសំណុំរឿងក្នុងគោលដៅ "ធ្វើការសង្ខេប" ដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ ប៉ុន្តែគឺដើម្បីផ្តល់មធ្យោបាយក្នុងការពិនិត្យចំណុចនីមួយៗនៃដីកាឱ្យបានស៊ីជម្រៅ។ ដូចដែលអង្គជំនុំជម្រះបានគូសបញ្ជាក់រួចមកហើយ ហេតុផលដែលបានជំរុញឱ្យអង្គជំនុំជម្រះចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺ៖ *"១) ដើម្បីបែងចែកសំណុំរឿង ០០២ ទៅជាផ្នែកៗ ដែលអាចគ្រប់គ្រងបាន ដែលផ្នែកនីមួយៗត្រូវការពេលខ្លីក្នុងការសម្រេច ២) ដើម្បីធានាថា ការជំនុំជម្រះដំណាក់កាលដំបូងបានរួមបញ្ចូលនូវការពិនិត្យយ៉ាងហ្មត់ចត់លើបញ្ហាជាមូលដ្ឋាន និងការចោទប្រកាន់នានាប្រឆាំងនឹងជនជាប់ចោទទាំងអស់ ៣) ដើម្បីផ្តល់នូវមូលដ្ឋានសម្រាប់ការពិនិត្យលម្អិតលើបទចោទ និងការចោទប្រកាន់នានា ដែលនៅសេសសល់ប្រឆាំងនឹងជនជាប់ចោទនៅក្នុងការជំនុំជម្រះលើកក្រោយ ៤) ដើម្បីប្រតិបត្តិតាមលំដាប់នៃព្រឹត្តិការណ៍ និង/ឬលំដាប់លំដោយនៃដីកាដំណោះស្រាយ តាមដែលអាចធ្វើទៅបាន (រវាងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៦) ៥)*

[39] "បណ្តឹងសាទុក្ខ" កថាខណ្ឌ ២៩ និង ៣០។

[40] យោងដូចខាងលើ កថាខណ្ឌ ២៥។

[41] យោងដូចខាងលើ កថាខណ្ឌ ១៦។

[42] យោងដូចខាងលើ កថាខណ្ឌ ៣១ និងកថាខណ្ឌបន្តបន្ទាប់។

*ដើម្បីជ្រើសរើសការចោទប្រកាន់លើអង្គហេតុទាំងឡាយ ដែលប៉ះពាល់ដល់ជនរងគ្រោះជាច្រើន តាមដែលធ្វើបាន។"* [43]។ ហេតុផលនេះពុំអាចឲ្យគេសន្និដ្ឋានបានថា អង្គជំនុំជម្រះបានរំលោភលើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនឡើយ។

៣២. ក្រៅអំពីអង្គហេតុដែលថា សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញាត្រូវបានធ្វើដោយយឺតយ៉ាវ ដោយហេតុថា សហព្រះរាជអាជ្ញាគួរតែលើកអំពីសេចក្តីជំទាស់នោះតាំងពីពេលដែលមានដីកាបំបែកសំណុំរឿង[44] វាក៏ជារឿងមួយដែលមិនត្រឹមត្រូវផងដែរ ក្នុងការដែលសហព្រះរាជអាជ្ញាបានស្នើសុំដល់តុលាការកំពូលឲ្យប្រើប្រាស់ការវាយតម្លៃផ្ទាល់របស់ខ្លួនស្តីអំពីកាលានុវត្តភាពនៃការបំបែកសំណុំរឿង ជំនួសឲ្យការវាយតម្លៃរបស់អង្គជំនុំជម្រះនោះ។

៣៣. ដោយឡែក ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវីបានលើកឡើង ហើយដែលការលើកឡើងនោះត្រូវបានធ្វើជាមូលដ្ឋានយោងដោយសហព្រះរាជអាជ្ញា៖

*"វាគឺជាយុត្តិសាស្ត្រមួយដែលគេតែងតែអនុវត្តដូចគ្នានៅតុលាការ ដែលថា បណ្តឹងសាទុក្ខដែលប្តឹងទាស់ទៅនឹងការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ពុំមែនជារឿងក្តីមួយដែលថ្មីនោះទេ។ នៅពេលដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍ពិនិត្យមើលលើការអនុវត្តអំណាចឆន្ទានុសិទ្ធិពីសំណាក់អង្គជំនុំជម្រះសាលាដំបូង បញ្ហាដែលចោទឡើងពុំមែនស្វែងរកឲ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងបានអនុម័តសេចក្តីសម្រេច ឬអត់នោះទេ ប៉ុន្តែត្រូវពិនិត្យមើលថា តើអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់អំណាចឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការចេញសេចក្តីសម្រេចហួសព្រំដែនកំណត់ឬទេ។ ដើម្បីឲ្យអង្គជំនុំជម្រះសាលាឧទ្ធរណ៍ធ្វើអន្តរាគមន៍ចូលទៅក្នុងសំណុំរឿងពាក់ព័ន្ធនិងការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ម្ចាស់បណ្តឹងសាទុក្ខត្រូវបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងពុំបានយកចិត្តទុកដាក់ទៅលើគោលការណ៍ដែលត្រូវអនុវត្ត ឬទៅលើវិធានច្បាប់ដែលត្រូវប្រកាន់យកក្នុងការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ឬបានភ្ជាប់*

[43] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E124/7** កថាខណ្ឌ ១០។

[44] សូមមើលខាងលើ ផ្នែកទីមួយនៃសេចក្តីសន្និដ្ឋានស្តីពីភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៣។

*ខ្លឹមសារទៅនឹងធាតុផ្សំនានាដែលស្ថិតនៅក្រៅសំណុំរឿង ឬពុំមានលក្ខណៈសមហេតុផល ឬដែលអង្គជំនុំជម្រះពុំបានពិនិត្យ ឬពិនិត្យពុំបានគ្រប់គ្រាន់ទៅលើធាតុផ្សំត្រឹមត្រូវនៃអង្គហេតុ ឬមានកំហុស ពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវបានប្រើជាមូលដ្ឋានក្នុងការអនុវត្តនូវអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ឬក៏សេចក្តីសម្រេចមានលក្ខណៈមិនសមហេតុសមផល ឬក៏មានលក្ខណៈខុសឆ្គងដែលធ្វើឱ្យអង្គជំនុំជម្រះសាលាឧទ្ធរណ៍អាចសន្និដ្ឋានបានថា អង្គជំនុំជម្រះសាលាដំបូងពុំបានអនុវត្តនូវអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវនោះ”*[45]។

៣៤. ក្នុងការប្រកាន់យកទស្សនាទានតែមួយគត់ដែលថា នឹងពុំមានការជំនុំជម្រះលើកទីពីរ ដោយគ្រាន់តែផ្អែកយ៉ាងសាមញ្ញលើស្ថានភាពជាក់ស្តែង សហព្រះរាជអាជ្ញាពុំបានបង្ហាញថាអង្គជំនុំជម្រះ “*ពុំបានគោរពតាមគោលការណ៍ដែលត្រូវអនុវត្ត ឬលើវិធានច្បាប់ដែលត្រូវគោរពតាមនោះ*”។ ផ្ទុយទៅវិញ រាល់ទឡ្ហីករណ៍ទាំងឡាយដែលបានបង្ហាញនៅចំពោះមុខតុលាការកំពូល ត្រូវបានលើកឡើងដោយសហព្រះរាជអាជ្ញានៅចំពោះមុខអង្គជំនុំជម្រះ[46] ដែលបានធ្វើការឆ្លើយតបរួចមកហើយនោះ[47]។

៣៥. អង្គជំនុំជម្រះក៏ធ្លាប់បានបង្ហាញចំពោះភាគីផងដែរថា *“ពុំមានការចោទប្រកាន់អំពីអង្គហេតុ ឬបទចោទណាមួយដែលបានលើកឡើងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានបោះបង់ចោល”* ហើយវាពុំមែនជា “*ការចាំបាច់ឡើយ ដែលការជំនុំជម្រះដំណាក់កាលដំបូង ត្រូវគ្របដណ្តប់លើបទចោទទាំងមូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ។”*[48]។

---

[45] *រដ្ឋអាជ្ញា ទល់នឹង Halilović* សំណុំរឿងលេខ IT-01-48 “សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗស្តីពីការដាក់បញ្ចូលទៅក្នុងសំណុំរឿង នូវឯកសារសម្លេងនៃការសួរចម្លើយជនជាប់ចោទ ដែលបានដាក់ដោយផ្ទាល់ដោយរដ្ឋអាជ្ញា” សាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៥ កថាខណ្ឌ ៥។

[46] ក្នុងន័យនេះ សូមមើលសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E124/2** កថាខណ្ឌ ២៤ ដល់ ៣៥។

[47] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E124/7** កថាខណ្ឌ ៩។

[48] យោងដូចខាងលើ កថាខណ្ឌ ៩។

៣៦. ដោយឡែក សហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួនថា សញ្ញាណ "ផលប្រយោជន៍នៃយុត្តិធម៌" ត្រូវតែបានបកស្រាយដោយពឹងផ្អែកទៅលើយុត្តិសាស្ត្រអន្តរជាតិ[49]។ សហព្រះរាជអាជ្ញាបានអះអាងថា សញ្ញាណនេះពុំត្រូវបានកំណត់និយមន័យដោយវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ដោយច្បាប់បង្កើត អ.វ.ត.ក និងដោយក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឡើយ អង្គជំនុំជម្រះតុលាការកំពូលត្រូវតែអនុវត្តនូវយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី ពាក់ព័ន្ធនិងករណីនេះ[50]។

៣៧. ជាមួយគ្នានេះ សហព្រះរាជអាជ្ញាបានរំលឹកផងដែរថា យោងតាមវិធាន ៧៣ ស្ទួន ឃ. នៃវិធានផ្ទៃក្នុងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី៖
*"បន្ទាប់ពីបានស្តាប់ព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូងអាច [...] កំណត់អំពីចំនួននៃទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្ម ឬអង្គហេតុដែលត្រូវចោទប្រកាន់នៅក្នុងបទចោទមួយ ឬច្រើន ដែលតាមរយៈនោះ ព្រះរាជអាជ្ញាអាចបង្ហាញនូវមធ្យោបាយភស្តុតាង ហើយ**ដែលតំណាងឱ្យឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់** ដោយគិតអំពីកាលៈទេសៈសមស្របទាំងឡាយ រួមទាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ការកំណត់បទល្មើស និងប្រភេទបទល្មើស ទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្ម វិសាលភាព និងជនរងគ្រោះផងដែរ"*[51]។

៣៨. មិនតែប៉ុណ្ណោះ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនិងសំណើសុំរបស់សហព្រះរាជអាជ្ញាឱ្យមានការពិនិត្យឡើងវិញលើដីកាបំបែកសំណុំរឿង *"នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី មាត្រា ៧៣ ស្ទួន នៃវិធាននីតិវិធី និងភស្តុតាងដែលបញ្ញត្តិឡើងក្នុងបរិបទនៃនីតិវិធីតទល់ចំពោះមុខ មានតែអយ្យការមួយគត់ដែលអាចដាក់ និងកែប្រែដីកាបញ្ជូនរឿងទៅជម្រះ។ **ផ្ទុយទៅវិញ វិធានស្រដៀងគ្នានេះមិនសមស្របទៅនឹង អ.វ.ត.ក នោះទេ នៅពេលដែលកិច្ចដំណើរការនីតិវិធីនៅអ.វ.ត.ក. មានលក្ខណៈជានីតិវិធីស៊ើបសួរដោយចៅក្រម** ហើយដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានគ្រប់គ្រងដោយ*

[49] "បណ្តឹងសាទុក្ខ" កថាខណ្ឌ ៣១។

[50] យោងដូចខាងលើ។

[51] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូស្លាវី *វិធាននីតិវិធី និងភស្តុតាង* IT/32/Rev. 47 ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២ វិធាន ៧៣ ស្ទួន ឃ.។ [គូសបញ្ជាក់បន្ថែមដោយអ្នកតាក់តែង]។

*សមត្ថកិច្ចតុលាការ ដែលឈានទៅដល់ការចេញសេចក្ដីសម្រេចតាក់តែងឡើងដោយចៅក្រម និងអាចប្ដឹងសាទុក្ខបាននោះ"*[52]។

៣៩. ដោយឡែក សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះពុំបានធ្វើការឆ្លើយតបទៅនឹងទឡ្ហីករណ៍ដែលតាមរយៈនោះ នៅពេលដែលការជំនុំជម្រះនាពេលអនាគតហាក់ដូចជាមិនអាចធ្វើទៅបាន បទចោទក្នុងសំណុំរឿងទីមួយត្រូវតែអាចតំណាងឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល[53]។ ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញានេះ មានលក្ខណៈខុសឆ្គង ដោយហេតុថា សហព្រះរាជអាជ្ញាបានធ្វើឱ្យស្របគ្នារវាងស្ថានភាពនីតិវិធីពីរដែលមានលក្ខណៈខុសគ្នាទាំងស្រុង ជាមួយនឹងវិធានដែលត្រូវអនុវត្ត ហើយដែលវិធានទាំងនោះក៏មានលក្ខណៈខុសគ្នាដែរ។

៤០. ជាក់ស្ដែង វិធាន ៧៣ ស្ទួន នៃវិធាននីតិវិធី និងវិធានភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី និងយុត្តិសាស្ត្រដែលពាក់ព័ន្ធនិងមាត្រានេះ[54] មានអត្ថន័យតែនៅក្នុងបរិបទដែលការជំនុំជំរះលើរឿងក្ដីជាច្រើនក្នុងសំណុំរឿងតែមួយ ត្រូវបានលុបចោលជាមុនដោយនីតិវិធីជាធរមាន។

៤១. ករណីនេះពុំមែនជាករណីដែលកើតឡើងនៅ អ.វ.ត.ក ទេ។ ផ្ទុយទៅវិញ នាខែ កុម្ភៈ ឆ្នាំ ២០១១ សម័យប្រជុំពេញអង្គរបស់ អ.វ.ត.ក បានសម្រេចមិនអនុវត្តតាមបទបញ្ញត្តិនៃមាត្រា ៧៣ ស្ទួន

---

[52] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E124/7** កថាខណ្ឌ ៩។ [គូសបញ្ជាក់បន្ថែមដោយអ្នកតាក់តែង]។

[53] "បណ្ដឹងសាទុក្ខ" កថាខណ្ឌ ៣៣។

[54] ពាក់ព័ន្ធនឹងប្រការនេះ សហព្រះរាជអាជ្ញាយោងជាអាទិ៍ទៅលើសំណុំរឿងនានាដូចខាងក្រោម៖ *រដ្ឋអាជ្ញា ទល់នឹង Ramush Haradinaj និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-0484-A "សេចក្ដីសម្រេចយោងតាមវិធាន ៧៣ ស្ទួន ឃ. សាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី" ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៧ កថាខណ្ឌ ១១; *រដ្ឋអាជ្ញា ទល់នឹង Vojislav Šešelj* សំណុំរឿងលេខ IT-03-67 "សេចក្ដីសម្រេចលើការអនុវត្តវិធាន ៧៣ ស្ទួន នៃវិធាននីតិវិធី និងភ័ស្តុតាង" សាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី" ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ១០ និង ១២ និង *រដ្ឋអាជ្ញា ទល់នឹង Milutinović* សំណុំរឿងលេខ IT-05-87 "សេចក្ដីសម្រេចលើការអនុវត្តវិធាន ៧៣ ស្ទួន នៃវិធាននីតិវិធី និងភ័ស្តុតាង" សាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី" ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ១១។

ឡើយ ហើយបានអនុម័តយកនូវបទបញ្ញត្តិដែលមានចែងនៅក្នុងវិធាន ៨៩ ស្ទួន ២ នៃវិធានផ្ទៃក្នុងវិញ[55]។ ដូចដែលអង្គជំនុំជម្រះបានគូសបញ្ជាក់ថា *"វិធាននេះមានបំណងផ្ដល់ឲ្យអង្គជំនុំជម្រះសាលាដំបូងនូវយន្តការគ្រប់គ្រងការជំនុំជម្រះក្ដីដែលអាចឲ្យអង្គជំនុំជម្រះបំបែកសំណុំរឿងតាមឆន្ទានុសិទ្ធិរបស់ខ្លួន និងអាចពិនិត្យមើលការជំនុំជម្រះដាច់ដោយឡែកពីគ្នាលើផ្នែកខុសៗគ្នានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលផលប្រយោជន៍នៃយុត្តិធម៌តម្រូវ។"*[56]។

៤២. យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី ដែលកំណត់អំពីសញ្ញាណនៃ"ផលប្រយោជន៍យុត្តិធម៌" ដែលត្រូវបានលើកជាសម្អាងដោយសហព្រះរាជអាជ្ញាមិនមានភាពស៊ីសង្វាក់គ្នាទៅនិងបរិបទនៃសំណុំរឿង ០០២/០១ ឡើយ។ សហព្រះរាជអាជ្ញាព្យាយាមបង្ហាញថា ការសម្រេចជំនុំជម្រះរឿងក្ដីទីពីរ មានភាពមិនច្បាស់លាស់ ដែលចំណុចនេះមានន័យថាបានបញ្ចប់នូវការចោទប្រកាន់នានាក្នុងការជំនុំជម្រះទីមួយ។ ដោយឡែក សហព្រះរាជអាជ្ញាពុំបានលើកឡើងនូវទឡ្ហីករណ៍គតិយុត្តិណាមួយដើម្បីធ្វើជាមូលដ្ឋាននៃសំណើរនេះឡើយ ហើយបែរជាលើកឡើងនូវយុត្តិសាស្ត្រដែលមានមូលដ្ឋានគតិយុត្តិផ្អែកលើវិធានច្បាប់ផ្ទុយគ្នាស្រឡះទៅនឹងវិធានច្បាប់ជាធរមានរបស់ អ.វ.ត.ក។

៤៣. ដូច្នេះ បណ្ដឹងសាទុក្ខមិនត្រឹមតែមិនបានធ្វើការបង្ហាញថាអង្គជំនុំជម្រះបានរំលោភលើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនត្រង់ចំណុចណានោះទេ ប៉ុន្តែថែមទាំងមិនបានបង្ហាញអំពីបញ្ហាគតិយុត្តិថ្មីដែលត្រូវដាក់ជូនតុលាការកំពូលធ្វើការសម្រេចទៀត។

## IV. <u>សេចក្ដីសម្រេចដែលត្រូវបានប្ដឹងសាទុក្ខមានលក្ខណៈផ្ទុយនៅនឹងទម្រង់ច្បាប់ និងគតិច្បាប់</u>

---

[55] ក្នុងន័យនេះ សូមមើល សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E124/7** កថាខណ្ឌ ៥។

[56] យោងដូចខាងលើ។

៤៤. សហព្រះរាជអាជ្ញាយល់ឃើញថា អង្គជំនុំជម្រះពុំបានគោរពដល់វិធានដែលត្រូវអនុវត្ត ដោយហេតុថា អង្គជំនុំជម្រះពុំបានលើកនូវអំណះអំណាងគ្រប់គ្រាន់ក្នុងសេចក្តីសម្រេចដែលត្រូវបានប្តឹងសាទុក្ខនោះ ហើយសេចក្តីសម្រេចនេះទៀតសោតក៏ពុំបានធ្វើឡើងក្នុងទម្រង់មួយសមស្របដែរ[57]។

៤៥. សហមេធាវីការពារក្តីលោក ខៀវ សំផន ក៏ធ្លាប់បានលើកឡើងអំពីភាពពុំច្បាស់លាស់ផ្លូវច្បាប់ពាក់ព័ន្ធទៅនិងការជូនដំណឹងរបស់អង្គជំនុំជម្រះស្តីអំពីសេចក្តីណែនាំនានា ក្រោមរូបភាពជាអនុស្សារណៈ ហើយសហមេធាវីការពារក្តីមិនបានធ្វើការជំទាស់ទៅនឹងទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនិងបញ្ហានេះទេ។

៤៦. ផ្ទុយទៅវិញ មេធាវីការពារក្តីមិនអាចគាំទ្រចំពោះទឡ្ហីករណ៍ទាំងឡាយដែលថា អង្គជំនុំជម្រះប្រហែលជាពុំបានផ្តល់សម្អាងគ្រប់គ្រាន់ដល់សេចក្តីសម្រេចរបស់ខ្លួននោះ។ តាមរយៈអនុស្សរណៈចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីទាំងអស់អំពីកិច្ចប្រជុំរៀបចំសវនាការ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ១៧ ខែ សីហា *"ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១* ***និងការអនុវត្តវិធានការបន្ថែម ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ។****"*[58]។

៤៧. នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំនោះ ក្រុមមេធាវីការពារក្តីនីមួយៗ បានលើកឡើងរៀងខ្លួននូវទឡ្ហីករណ៍នានា ដែលមេធាវីការពារក្តីយល់ឃើញថា ការពន្យាពេលរឿងក្តីទីមួយ ទោះបីជាមានដែនកំណត់ក៏ដោយ នឹងបណ្តាលឲ្យមានការអូសបន្លាយនីតិវិធី ហើយអាចនឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប។

៤៨. ដោយផ្អែកលើទឡ្ហីករណ៍ទាំងឡាយដែលលើកឡើងដោយភាគីនីមួយៗ អង្គជំនុំជម្រះបានអនុម័តនូវសេចក្តីសម្រេចរបស់ខ្លួន ដោយមានអំណះអំណាងដូចខាងក្រោម៖

---

[57] "បណ្តឹងសាទុក្ខ" កថាខណ្ឌ ៤២ និងកថាខណ្ឌបន្តបន្ទាប់។

[58] ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែម ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ, អនុស្សរណៈចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ ឯកសារ **E218**។ [គូសបញ្ជាក់បន្ថែមដោយអ្នកតាក់តែង]។

*“បន្ទាប់ពីមានកិច្ចពិភាក្សាអំពីចំណុចបន្ថែមដែលត្រូវបានស្នើសុំដាក់បញ្ចូលទាំងនេះ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការកាលពីពេលកន្លងទៅថ្មីៗ និងបន្ទាប់ពីការពិចារណាយ៉ាងម៉ត់ចត់អំពីរាល់ការលើកឡើងរបស់ភាគីនានានៅក្នុងកិច្ចប្រជុំ ក៏ដូចជាក្រោយកិច្ចប្រជុំរៀបចំសវនាការនោះ អង្គជំនុំជម្រះយល់ឃើញថា សំណើសុំពង្រីកវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ដើម្បីដាក់បញ្ចូលការចោទប្រកាន់អង្គហេតុនានាពាក់ព័ន្ធនឹងមន្ទីរ ស-២១ និងស្រុក ១២ មិនអាចទទួលយកបានឡើយ។* ***ជាបឋម មូលហេតុនៃការយល់ឃើញដូច្នេះ គឺមកពីការ ដាក់បញ្ចូលធាតុផ្សំទាំងនេះ*** *(មិនថាដោយសារចំនួនសាក្សីដែលភាគីបានស្នើសុំកោះហៅ ការលំបាកដែលបានរំពឹងទុកក្នុងការកំហិតវិសាលភាពនៃចំណុចអង្គហេតុបន្ថែមដែលត្រូវបានស្នើសុំទាំងនេះ ឬការជំទាស់របស់មេធាវីការពារក្តីដែលអាចមានចំពោះចំណុចអង្គហេតុបន្ថែមទាំងនេះឡើយ)* ***នឹងអាចធ្វើឱ្យសវនាការលើសំណុំរឿង ០០២/០១ អូសបន្លាយពេលយូរ។***”[59]

៤៩. សារណារបស់សហព្រះរាជអាជ្ញាដែលថា អង្គជំនុំជម្រះបានធ្វើការកែប្រែជំហររបស់ខ្លួនទាំងស្រុង ដោយពុំបានពន្យល់អំពីហេតុផល[60] គឺជាសារណាដែលមានលក្ខណៈខុសឆ្គង។ ផ្ទុយទៅវិញ ខុសអំពីអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើង អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចមានសម្អាងហេតុច្បាស់លាស់ ដោយបានពិចារណាអំពីហានិភ័យនៃការពង្រីកវិសាលភាពសំណុំរឿងទីមួយនាដំណាក់កាលនៃកិច្ចពិភាក្សានេះ។

## V. ការវាយតម្លៃអំពីហានិភ័យនៃការពន្យាពេលសវនាការ

៥០. សហព្រះរាជអាជ្ញាបានអះអាងថា ការណ៍ដែលអង្គជំនុំជម្រះចាត់ទុកសេចក្តីជំទាស់ដែលមេធាវីការពារក្តីអាចលើកឡើង ថាជាកត្តារួមផ្សំមួយដែលអាចនាំទៅរកការពន្យាពេលនៃរឿងក្តី គឺជាកំហុសឆ្គងមួយលើអង្គហេតុ និងអង្គច្បាប់[61]។

៥១. សហព្រះរាជអាជ្ញាបានប្រកាសថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះគឺជាសេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខបាន។ សេចក្តីសម្រេចទាំងនោះមិនគួរត្រូវបានជំទាស់ ឬរិះគន់នៅក្នុងដំណាក់កាល

---

[59] “សេចក្តីសម្រេចដែលរងការជំទាស់” កថាខណ្ឌ ២។ [គូសបញ្ជាក់បន្ថែមដោយអ្នកតាក់តែង]។

[60] “បណ្តឹងសាទុក្ខ” កថាខណ្ឌ ៤៨។

[61] យោងដូចខាងលើ កថាខណ្ឌ ៥១។

នៃនីតិវិធីទេ[62]។ ជាមួយគ្នានេះ សហព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានថា បន្ទាប់ពីមានសេចក្តីសម្រេចស្តីអំពីវិសាលភាពនៃរឿងក្តី ពុំមាន"សេចក្តីជំទាស់"ណាមួយរបស់មេធាវីការពារ ដែលនាំឲ្យមានជាការពន្យាពេលនៃរឿងក្តីឡើយ[63]។

៥២. សហព្រះរាជអាជ្ញាបានធ្វើការរិះគន់ផងដែរទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ត្រង់ចំណុចដែលថាសេចក្តីសម្រេចនោះបានធ្វើការពិចារណាទៅលើ "ផលលំបាកជាក់ច្បាស់ ក្នុងការស្វែងរកមធ្យោបាយនានាដែលអនុញ្ញាតិឲ្យគេអាចធ្វើការអូសបន្លាយណាមួយ ក្នុងព្រំដែនដែលសមស្របនោះ[64]"។

៥៣. អំណះអំណាងដូច្នេះបានធ្វើកាត់ផ្តាច់តួនាទីរបស់អង្គជំនុំជម្រះក្នុងការធានានូវយុត្តិធម៌នៃនីតិវិធី និងការគោរពសិទ្ធិជាសារវន្តរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះត្រូវបំពេញនូវតួនាទីរបស់ខ្លួនក្នុងការធានាថាសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការកាត់សេចក្តីក្នុងរយៈពេលមួយសមស្រប ត្រូវបានគោរព។ ដោយឡែក ដូចដែលបានលើកឡើងជាច្រើនលើកច្រើនសារនៅក្នុងយុត្តិសាស្ត្រអន្តរជាតិ សិទ្ធិនេះត្រូវតែបានគេយកចិត្តទុកដាក់ ដោយរួមទាំងសិទ្ធិដទៃទៀតដែលជនជាប់ចោទទទួលបាន ជាពិសេសសិទ្ធិទទួលបានការជូនដំណឹងលម្អិតអំពីប្រភេទនៃបន្ទុកដែលធ្លាក់ទៅលើពួកគេ[65]។

៥៤. នេះជាហេតុផលមួយដែលមេធាវីការពារក្តីមានបំណងចង់ឲ្យអង្គជំនុំជម្រះធ្វើការចាប់អារម្មណ៍ថាការពង្រីកវិសាលភាពនៃសំណុំរឿងទីមួយ អស់រយៈពេលជាងមួយឆ្នាំបន្ទាប់ពីមានដីកាបំបែក

---

[62] យោងដូចខាងលើ កថាខណ្ឌ ៥៣។

[63] យោងដូចខាងលើ។

[64] "បណ្តឹងសាទុក្ខ" កថាខណ្ឌ ៥៤។

[65] សូមមើលខាងលើ ឯកសារនានាក្នុងកថាខណ្ឌ ២៣ និង ៣២។ សូមមើលផងដែរ៖ *រដ្ឋអាជ្ញា ទល់នឹង Karemera* សំណុំរឿងលេខ ICTR-98-44 *សេចក្តីសម្រេចលើការបំបែកសំណុំរឿង Andre Rwamakuba និងសំណើសុំអនុញ្ញាតដាក់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានកែប្រែ* ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ កថាខណ្ឌ ៣៥; *រដ្ឋអាជ្ញា ទល់នឹង Simba* សំណុំរឿងលេខ ICTR-2001-76-I *សេចក្តីសម្រេចលើញត្តិសុំកែប្រែការបញ្ជូនរឿងទៅជំនុំជម្រះ* ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៤ កថាខណ្ឌ ៨ និង *រដ្ឋអាជ្ញា ទល់នឹង Muhimana* សំណុំរឿងលេខ ICTR-1995-1b-I, *Decision on Motion to Leave Indictment* ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៥ កថាខណ្ឌ ១៧។

សំណុំរឿងចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២[66] បានបង្កើតជាផលវិបាកនានាដល់មេធាវីការពារក្ដី ក្នុងការគ្រប់គ្រងក្រុមមេធាវីរបស់ខ្លួន និងក្នុងការងារត្រៀមរៀបចំការពារកូនក្ដីរបស់ខ្លួន ។

៥៥. ដូច្នេះ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះត្រូវបានធ្វើដោយផ្អែកលើអំណះអំណាងស្របច្បាប់ទាំងនេះ ហើយមិនអាចត្រូវបានចាត់ទុកពីសំណាក់តុលាការកំពូលថាមានលក្ខណៈខុសឆ្គង ឬមិនសមហេតុផល ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រឡំក្នុងការវាយតម្លៃនោះឡើយ”[67] ។

៥៦. **ហេតុដូច្នេះ** មេធាវីការពារក្ដីលោក ខៀវ សំផន សូមស្នើដល់តុលាការកំពូល មេត្តា៖

- **ប្រកាសថា** បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាមិនអាចទទួលយកបានឡើយ។ ក្នុងគ្រប់ករណីទាំងអស់
- **បដិសេធចោល** បណ្ដឹងសាទុក្ខ លើគ្រប់អំណះអំណាងទាំងអស់។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br>មេធាវី Anta GUISSÉ<br>មេធាវី Arthur VERCKEN<br>មេធាវី Jacques VERGÈS | ភ្នំពេញ<br>ភ្នំពេញ<br>ប៉ារីស<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |

[66] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **E124**។

[67] *រដ្ឋអាជ្ញា ទល់នឹង Jadranko Prlić និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-74 *“សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់សាលាដំបូងលើសំណើសុំដោះលែងជាបណ្ដោះអាសន្ន ដែលបានដាក់ដោយ Slobodan Praljak”* សាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ចុះថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៩ កថាខណ្ឌ ៥។